គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០០៥/១៧ គ.ម.ក./ប្រ.ក.

# ប្រកាស
## ស្តីពី
## ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-** គោលបំណង

ប្រកាសនេះមានគោលបំណងកំណត់ពីលក្ខខណ្ឌតម្រូវដើម្បីទទួលស្គាល់ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យក្នុងវិស័យមូលបត្រ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-** និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន÷

១-*ក្រម**សីលធម៌វិជ្ជាជីវៈ*** សំដៅដល់គោលការណ៍ តម្លៃ ស្តង់ដា ឬវិធាននានាដែលកំណត់អំពីឥរិយាបទរបស់គណនេយ្យករ និងសវនករក្នុងវិជ្ជាជីវៈរបស់ខ្លួន។

២-*ក្រុមហ៊ុនផ្តល់សេវាសវនកម្ម* សំដៅដល់សវនករជានីតិបុគ្គលដែលបង្កើតឡើងស្របតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

៣-*សវនករឯករាជ្យ* សំដៅដល់សវនករជារូបវន្តបុគ្គលដែលជាសមាជិកសកម្មរបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ហើយបម្រើការងារនៅក្នុងក្រុមហ៊ុនផ្តល់សេវាសវនកម្ម។

៤-*សវនកម្ម* សំដៅដល់ការត្រួតពិនិត្យ និងវាយតម្លៃដោយឯករាជ្យ និងជាប្រព័ន្ធ លើទិន្នន័យរបាយការណ៍កំណត់ត្រា កិច្ចប្រតិបត្តិការ និងលទ្ធផលជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុរបស់សហគ្រាសសម្រាប់គោលបំណងជាក់លាក់ណាមួយ។

៥-*របាយការណ៍របស់អ្នកគ្រប់គ្រង* **(Management Letter)** សំដៅដល់អនុសាសន៍របស់សវនករឯករាជ្យផ្ញើទៅឱ្យគណៈគ្រប់គ្រងរបស់ក្រុមហ៊ុនរងសវនកម្ម កត់សម្គាល់ពីចំណុចខ្សោយដែលរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ឬត្រួតពិនិត្យឡើងវិញ ដើម្បីជាមូលដ្ឋានសម្រាប់ចេញរបាយការណ៍សវនកម្ម។

## ជំពូកទី ២
## លក្ខខណ្ឌ និងនីតិវិធីសម្រាប់ការទទួលស្គាល់

**ប្រការ ៣.-** លក្ខខណ្ឌសម្រាប់ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម

បុគ្គលដែលមានបំណងធ្វើជាក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ ត្រូវដាក់ពាក្យស្នើសុំការទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១-ត្រូវធ្វើប្រតិបត្តិការស្របតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ

២-ត្រូវមានសវនករឯករាជ្យយ៉ាងតិចចំនួន ២ (ពីរ) រូប ដែលសវនករឯករាជ្យទាំងនោះត្រូវបំពេញនូវលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះ

៣-ត្រូវមានការធានារ៉ាប់រងវិជ្ជាជីវៈ

៤-ត្រូវបានបង្កើត និងមានសកម្មភាពធុរកិច្ច ព្រមទាំងមានបទពិសោធន៍ធ្វើសវនកម្មដល់ក្រុមហ៊ុនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា

៥-ត្រូវមានកេរ្តិ៍ឈ្មោះល្អក្នុងសកម្មភាពធុរកិច្ចសវនកម្ម

៦-ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់រយៈពេលយ៉ាងតិច១(មួយ) ការិយបរិច្ឆេទគណនេយ្យចុងក្រោយ

៧-ត្រូវមានយន្តការត្រួតពិនិត្យគុណភាពសវនកម្ម (Audit Quality Control System) ដោយអនុលោមតាមស្តង់ដាវិជ្ជាជីវៈដែលមានជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤**.-ពាក្យស្នើសុំសម្រាប់ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម

បុគ្គលដាក់ពាក្យស្នើសុំការទទួលស្គាល់ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

១-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម

២-វិញ្ញាបនបត្របញ្ជាក់ជាសមាជិកសកម្មរបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ

៣-អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ចេញដោយក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ.) ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ

៤-បញ្ជីសវនករឯករាជ្យដែលជាសមាជិកសកម្មមានលក្ខណៈបច្ចុប្បន្នភាព និងភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេបរបស់សវនករឯករាជ្យនីមួយៗ ដោយបញ្ជាក់ពីរយៈពេលបំពេញការងារ និងបទពិសោធន៍

៥-របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មសម្រាប់រយៈពេលយ៉ាងតិច ១ (មួយ) ការិយបរិច្ឆេទគណនេយ្យចុងក្រោយ មុនពេលដាក់ពាក្យស្នើសុំការទទួលស្គាល់

៦-បញ្ជីឈ្មោះអតិថិជនដែលបានធ្វើសវនកម្ម

៧-របាយការណ៍ប្រតិបត្តិការ និងការប្រែប្រួលសំខាន់ៗដែលមានផលប៉ះពាល់ដល់ដំណើការ និងលទ្ធផលប្រតិបត្តិការសម្រាប់ការិយបរិច្ឆេទគណនេយ្យចុងក្រោយ

៨-របាយការណ៍ស្តីពីការប្រែប្រួលសំខាន់ៗក្នុងការិយបរិច្ឆេទគណនេយ្យចុងក្រោយ ពាក់ព័ន្ធនឹងសវនករឯករាជ្យ ដូចជាការកើន ឬថយចុះនៃចំនួនសវនករឯករាជ្យ ការបំពានបទប្បញ្ញត្តិ និងក្រមសីលធម៌វិជ្ជាជីវៈរបស់សវនករឯករាជ្យជាដើម

៩-យន្តការត្រួតពិនិត្យគុណភាពសវនកម្ម ដែលអនុលោមតាមស្តង់ដាវិជ្ជាជីវៈដែលមានជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ដោយត្រូវរៀបរាប់ឱ្យបានច្បាស់លាស់អំពីនីតិវិធីក្នុងការត្រួតពិនិត្យគុណភាពសវនកម្ម នីតិវិធីក្នុងការតាមដានការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈ និងឯករាជ្យភាព ព្រមទាំងគោលការណ៍ត្រួតពិនិត្យគុណភាពសវនកម្មដទៃទៀតជាដើម

១០-ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៥.**- លក្ខខណ្ឌសម្រាប់ការទទួលស្គាល់សវនករឯករាជ្យ

សវនករឯករាជ្យនៃក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលស្នើសុំការទទួលស្គាល់នៅ **គ.ម.ក.** ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១-ជាសមាជិកសកម្មរបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា

២-មានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ចេញដោយ ក.ជ.គ. ដែលមានសុពលភាព

៣-ត្រូវមានបទពិសោធន៍អនុវត្តការងារសវនកម្មយ៉ាងតិចចំនួន ៥ (ប្រាំ) ឆ្នាំ

៤-មិនធ្លាប់ប្រព្រឹត្តល្មើសនឹងក្រមសីលធម៌វិជ្ជាជីវៈ

៥-មិនធ្លាប់ត្រូវបានផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ក្នុងរយៈពេល ១០ (ដប់) ឆ្នាំ មុនពេលដាក់ពាក្យស្នើសុំ។

**ប្រការ ៦.**- ពាក្យស្នើសុំសម្រាប់ការទទួលស្គាល់សវនករឯករាជ្យ

សវនករឯករាជ្យដែលដាក់ពាក្យស្នើសុំការទទួលស្គាល់ ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលបានកំណត់ដោយ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម÷

១-សញ្ញាបត្រគណនេយ្យករជំនាញ (Certified Public Accountant-CPA) ឬសញ្ញាបត្រសមមូល

២-វិញ្ញាបនបត្របញ្ជាក់ជាសមាជិកសកម្មចេញដោយស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ

៣-អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ចេញដោយ ក.ជ.គ. ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ

៤-លិខិតបញ្ជាក់ថាសវនករឯករាជ្យមិនធ្លាប់ទទួលទណ្ឌកម្មរដ្ឋបាល

៥-លិខិតថ្កោលទោសដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច

៦-ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការស្នើសុំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៧.**- សុពលភាពនៃការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ

ការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ មានសុពលភាពរយៈពេល ៣ (បី) ឆ្នាំ។ ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃមុនការទទួលស្គាល់អស់សុពលភាព ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យដែលមានបំណងបន្តផ្តល់សេវា ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពនៃការទទួលស្គាល់ តាមទម្រង់ដែលកំណត់ដោយ **គ.ម.ក.**។

**ប្រការ ៨.-** រយៈពេលនៃការជូនដំណឹងចំពោះបុគ្គលដាក់ពាក្យស្នើសុំ

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងអំពីការទទួលស្គាល់ ឬការមិនទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីទទួលបានឯកសារពេញលេញ។

## ជំពូកទី ៣

## លក្ខខណ្ឌប្រតិបត្តិការរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ

**ប្រការ ៩.-** ការជ្រើសរើសក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ

ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ប្រតិបត្តិកររក្សាទុកមូលបត្រ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ បុគ្គលចុះបញ្ជីលក់មូលបត្រ ក្រុមហ៊ុនសមភាគីកណ្តាល ក្រុមហ៊ុនឈ្មួញជើងសាឧបករណ៍និស្សន្ទ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស (Trustee) ក្រុមហ៊ុនអភិបាលមូលនិធិ (Funds Administrator) បុគ្គលគ្រប់គ្រងមូលនិធិ (Funds Manager) និងក្រុមហ៊ុនដទៃទៀតដែលធ្វើធុរកិច្ចនៅក្នុងវិស័យមូលបត្រ ត្រូវជ្រើសរើសឱ្យធ្វើសវនកម្មក្នុងចំណោមក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ និងផ្សព្វផ្សាយជាផ្លូវការដោយ **គ.ម.ក.**។

**ប្រការ ១០.-** លក្ខខណ្ឌដែលមិនអនុញ្ញាតឱ្យធ្វើសវនកម្ម

ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ មិនត្រូវផ្តល់សេវាសវនកម្មឱ្យក្រុមហ៊ុនរងសវនកម្មដែលខ្លួនទទួលផលប្រយោជន៍ ឬមានសិទ្ធិគ្រប់គ្រង ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី តាមរយៈសហព័ទ្ធ ញាតិលោហិតឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ ឬមានទំនាក់ទំនងផ្សេងទៀតដែលអគ្គនាយកនៃ **គ.ម.ក.** យល់ឃើញថាអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍ជាមួយក្រុមហ៊ុនរងសវនកម្ម។

**ប្រការ ១១.-** សេវាមិនមែនសវនកម្មដែលត្រូវបានហាមឃាត់

ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ មិនត្រូវផ្តល់ដល់ក្រុមហ៊ុនរងសវនកម្មនូវសេវាដូចខាងក្រោម÷

១-ការកាន់បញ្ជីគណនេយ្យ ឬសេវាផ្សេងទៀតទាក់ទងនឹងកំណត់ត្រាគណនេយ្យ ឬរបាយការណ៍ហិរញ្ញវត្ថុ

២-ការរៀបចំ និងការដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានហិរញ្ញវត្ថុ

៣-សេវាវាយតម្លៃ ការប៉ាន់ស្មាន ការផ្តល់យោបល់ ឬការចូលរួមធ្វើរបាយការណ៍ទាំងនេះ

៤-សេវាពាក់ព័ន្ធនឹងការកំណត់សោធននិវត្តន៍បុគ្គលិក

៥-សេវាសវនកម្មផ្ទៃក្នុង

៦-សេវាមុខងារគ្រប់គ្រង ឬធនធានមនុស្ស

៧-សេវាធានាទិញមូលបត្រ ជួញដូរមូលបត្រ ជើងសាមូលបត្រ ឬផ្តល់ប្រឹក្សាវិនិយោគ

៨-សេវាផ្នែកច្បាប់

៩-សេវាប្រឹក្សាផ្នែកពន្ធ

១០-សេវាផ្សេងទៀតដែលអគ្គនាយកនៃ **គ.ម.ក.** យល់ឃើញថា អាចបង្កឱ្យមានទំនាស់ផលប្រយោជន៍។

ករណីក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ បានផ្តល់សេវាណាមួយដូចបានរៀបរាប់ខាងលើ ដល់ក្រុមហ៊ុនណាមួយ ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ មិនត្រូវផ្តល់សេវាសវនកម្មដល់ក្រុមហ៊ុន នោះក្នុងរយៈពេល ៣ (បី) ឆ្នាំ ក្រោយការផ្តល់សេវាខាងលើបានបញ្ចប់។

## ជំពូកទី ៤

## កាតព្វកិច្ចរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យដែលទទួលបានការទទួលស្គាល់

**ប្រការ ១២.**-របាយការណ៍ហិរញ្ញវត្ថុដែលត្រូវធ្វើសវនកម្ម ឬពិនិត្យឡើងវិញ

ក្រុមហ៊ុនផ្តល់សេវាសវនកម្មនិងសវនករឯករាជ្យដែលទទួលបានការទទួលស្គាល់មានកាតព្វកិច្ចធ្វើសវនកម្ម និងពិនិត្យឡើងវិញ នូវរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាដែលបានអនុម័តឱ្យប្រើនៅព្រះរាជាណាចក្រកម្ពុជា និងរបាយការណ៍ផ្សេងទៀតទៅតាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក**។

**ប្រការ ១៣.**- ការអនុវត្តស្តង់ដា

ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យដែលទទួលបានការទទួលស្គាល់ ត្រូវអនុវត្តឱ្យបាន ខ្ជាប់ខ្ជួនដូចខាងក្រោម÷

១- ស្តង់ដាគណនេយ្យដែលបានអនុម័តឱ្យប្រើនៅព្រះរាជាណាចក្រកម្ពុជា

២- ស្តង់ដាសវនកម្មដែលបានអនុម័តឱ្យប្រើនៅព្រះរាជាណាចក្រកម្ពុជា

៣- ក្រមសីលធម៌វិជ្ជាជីវៈ

៤- ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ប្រការ ១៤.**- កាតព្វកិច្ចរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ

ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យដែលទទួលបានការទទួលស្គាល់ មានកាតព្វកិច្ចដូច ខាងក្រោម÷

១- ត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច១ ចំណុច២ ចំណុច៣ ចំណុច៥ និងចំណុច៧ នៃ ប្រការ ៣ នៃប្រកាសនេះ។

២- ត្រូវគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច១ ចំណុច២ ចំណុច៤ និងចំណុច៥ នៃប្រការ ៥ នៃ ប្រកាសនេះ។

៣- ត្រូវពន្យល់ ឬផ្តល់ព័ត៌មាន និងទិន្នន័យដែលទាក់ទងនឹងសកម្មភាពសវនកម្ម ករណីមានការស្នើសុំ ដោយអគ្គនាយកនៃ **គ.ម.ក.**។

៤- ផ្តល់កិច្ចសហការដល់មន្ត្រីរបស់ **គ.ម.ក.** ក្នុងការត្រួតពិនិត្យលើយន្តការត្រួតពិនិត្យគុណភាពសវនកម្ម។

៥- នៅពេលធ្វើសវនកម្ម ប្រសិនបើរកឃើញថារបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មមិនបានអនុវត្ត ទៅតាមបញ្ញត្តិដូចមានចែងក្នុងប្រការ១៣នៃប្រកាសនេះ ត្រូវជូនដំណឹងដល់ក្រុមហ៊ុនរងសវនកម្ម និងស្នើឡើងវិញ

នូវវិធានការការពារ កែតម្រូវ និងដោះស្រាយចំពោះការបំពានទាំងនោះ ព្រមទាំងផ្តល់នូវអនុសាសន៍ចំពោះកំហុស ឬការបំពាននានាដែលមិនទាន់បានដោះស្រាយស្របទៅតាមស្តង់ដាសវនកម្ម ហើយត្រូវរាយការណ៍ក្នុងរបាយ-ការណ៍សវនកម្ម និងរបាយការណ៍របស់អ្នកគ្រប់គ្រងនោះ។

៦-នៅក្នុងកិច្ចសន្យាធ្វើសវនកម្មជាមួយអតិថិជន ត្រូវមានចែងអំពីសិទ្ធិរបស់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ ក្នុងការផ្តល់ព័ត៌មាន និងរបាយការណ៍សវនកម្មជូន **គ.ម.ក.**។

៧-ករណីអគ្គនាយកនៃ **គ.ម.ក.** តម្រូវឱ្យក្រុមហ៊ុនផ្តល់សេវាសវនកម្មពិនិត្យឡើងវិញចំពោះចំណុចមួយចំនួនដែលមិនមានភាពច្បាស់លាស់ ក្រុមហ៊ុនផ្តល់សេវាសវនកម្មត្រូវអនុវត្តតាមការស្នើសុំរបស់អគ្គនាយកនៃ **គ.ម.ក.**។

៨-ករណីអគ្គនាយកនៃ **គ.ម.ក.** រកឃើញថា ក្រុមហ៊ុនផ្តល់សេវាសវនកម្មបានចេញនូវរបាយការណ៍សវនកម្មដែលមិនត្រឹមត្រូវ ហើយបណ្តាលឱ្យមានការខូចខាតដល់ក្រុមហ៊ុនរងសវនកម្ម និងអ្នកប្រើប្រាស់របាយ-ការណ៍សវនកម្ម ក្រុមហ៊ុនផ្តល់សេវាសវនកម្មនោះត្រូវទូទាត់សងស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៩-ត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍អាជីវកម្មក្នុងវិស័យមូលបត្រប្រចាំត្រីមាសទៅតាមទម្រង់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ក្នុងរយៈពេល ១ (មួយ) ខែបន្ទាប់ពីដំណាច់ត្រីមាសនីមួយៗ និងរបាយ-ការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំក្នុងរយៈពេល ៣ (បី) ខែ បន្ទាប់ពីដំណាច់ការិយបរិច្ឆេទគណនេយ្យ ឬបន្ទាប់ពីពេលវេលាណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនេះត្រូវធ្វើសវនកម្មដោយក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**។ ក្នុងករណីមិនអាចរកបានក្នុងចំណោមក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ដែលត្រូវធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនោះ អាចជ្រើសរើសក្រុមហ៊ុនផ្តល់សេវាសវនកម្មផ្សេងទៀត ដោយមានការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។

១០-ត្រូវរាយការណ៍ជូនអគ្គនាយកនៃ **គ.ម.ក.** នៅពេលរកឃើញភាពមិនប្រក្រតីណាមួយដូចខាងក្រោម÷

ក-ការកែបន្លំ ឬកំហុសសំខាន់ៗរបស់ក្រុមហ៊ុនរងសវនកម្មដែលមានផលប៉ះពាល់ដល់ការសម្រេច-ចិត្តរបស់វិនិយោគិនមូលបត្រ ឬបុគ្គលពាក់ព័ន្ធដទៃទៀត។

ខ-ការបាត់បង់ ឬការបាត់បង់ជាសក្តានុពលសរុបចាប់ពី ១០ (ដប់) ភាគរយនៃទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុនរងសវនកម្ម។

គ-ទ្រព្យសកម្មរបស់ក្រុមហ៊ុនរងសវនកម្ម មិនគ្រប់គ្រាន់សម្រាប់ការទូទាត់ឱ្យម្ចាស់បំណុល។

ឃ-ក្រុមហ៊ុនរងសវនកម្មមិនមានយន្តការត្រួតពិនិត្យផ្ទៃក្នុងច្បាស់លាស់ ដែលអាចធ្វើឱ្យមានផលប៉ះពាល់ដល់ការរាយការណ៍ហិរញ្ញវត្ថុ។

១១-ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជូនអគ្គនាយកនៃ **គ.ម.ក.** ក្នុងរយៈពេលមិនលើសពី ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ ក្នុងករណីណាមួយដូចខាងក្រោម÷

-ការសុំឈប់ ការបញ្ឈប់ ឬការផ្អាកផ្តល់សេវាក្នុងវិស័យមូលបត្រ ដោយគិតចាប់ពីកាលបរិច្ឆេទសម្រេចដោយក្រុមហ៊ុនផ្តល់សេវាសវនកម្ម។

-ទទួលទណ្ឌកម្មណាមួយដូចមានចែងក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ឬបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដោយគិតចាប់ពីកាលបរិច្ឆេទទទួលបានលិខិតស្តីពីទណ្ឌកម្មនោះ។

-ការព្យួរ ឬដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ដោយគិតចាប់ពីកាលបរិច្ឆេទទទួលបានលិខិតស្តីពីការព្យួរ ឬដកហូតនោះ។

-កែប្រែលក្ខន្តិកៈក្រុមហ៊ុន ដោយត្រូវភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃលក្ខន្តិកៈដែលបានកែប្រែរួចនោះ បន្ទាប់ពីទទួលបានការចុះបញ្ជីកែប្រែនៅក្រសួងពាណិជ្ជកម្ម។

-ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការទិញយក (M&A) បន្ទាប់ពីមានការសម្រេចរបស់ក្រុមហ៊ុន។

-មានបញ្ហាស្ថានភាពហិរញ្ញវត្ថុធ្ងន់ធ្ងរដែលអាចឈានទៅរកក្ស័យធន។

១២-ត្រូវផ្តល់ឯកសារពាក់ព័ន្ធ និងអនុវត្តកាតព្វកិច្ចផ្សេងទៀតដែលតម្រូវដោយអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៥
## កម្រៃ និងបន្ទុក

**ប្រការ ១៥.-** ថ្លៃពាក្យស្នើសុំការទទួលស្គាល់របស់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម

ក្រុមហ៊ុនផ្តល់សេវាសវនកម្មត្រូវបង់ថ្លៃពាក្យស្នើសុំការទទួលស្គាល់ និងសោហ៊ុយសិក្សាសំណុំលិខិតជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល នៅពេលដាក់ពាក្យស្នើសុំទទួលស្គាល់។

ក្រុមហ៊ុនផ្តល់សេវាសវនកម្មត្រូវបង់ថ្លៃពាក្យស្នើសុំបន្តការទទួលស្គាល់ និងសោហ៊ុយសិក្សាសំណុំលិខិតជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល នៅពេលដាក់ពាក្យស្នើសុំបន្តទទួលស្គាល់។

**ប្រការ ១៦.-** ថ្លៃពាក្យស្នើសុំការទទួលស្គាល់របស់សវនករឯករាជ្យ

សវនករឯករាជ្យនីមួយៗត្រូវបង់ថ្លៃពាក្យស្នើសុំការទទួលស្គាល់ និងសោហ៊ុយសិក្សាសំណុំលិខិតជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល នៅពេលដាក់ពាក្យស្នើសុំទទួលស្គាល់។

សវនករឯករាជ្យនីមួយៗត្រូវបង់ថ្លៃពាក្យស្នើសុំបន្តការទទួលស្គាល់ និងសោហ៊ុយសិក្សាសំណុំលិខិតជាប្រាក់ចំនួន ៥០០.០០០ (ប្រាំរយពាន់) រៀល នៅពេលដាក់ពាក្យស្នើសុំបន្តទទួលស្គាល់។

**ប្រការ ១៧.-** ថ្លៃសេវាទទួលស្គាល់ប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម

ក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលទទួលបានការទទួលស្គាល់ ត្រូវបង់ថ្លៃសេវាទទួលស្គាល់ប្រចាំឆ្នាំជូន **គ.ម.ក.** ជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល ដោយគិតចាប់ពីកាលបរិច្ឆេទនៃការទទួលស្គាល់។ សម្រាប់ឆ្នាំដំបូង សេវាទទួលស្គាល់ប្រចាំឆ្នាំត្រូវបង់នៅពេលដែលទទួលបានការទទួលស្គាល់។ សម្រាប់ឆ្នាំបន្តបន្ទាប់ សេវាទទួលស្គាល់ប្រចាំឆ្នាំត្រូវបង់យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃខែនៃការទទួលស្គាល់នៃឆ្នាំបន្តបន្ទាប់នោះ។

**ប្រការ ១៨**.-ថ្លៃសេវាទទួលស្គាល់ប្រចាំឆ្នាំសម្រាប់សវនករឯករាជ្យ

សវនករឯករាជ្យនីមួយៗដែលទទួលបានការទទួលស្គាល់ ត្រូវបង់ថ្លៃសេវាទទួលស្គាល់ប្រចាំឆ្នាំជូន **គ.ម.ត.** ជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ដោយគិតចាប់ពីកាលបរិច្ឆេទនៃការទទួលស្គាល់។ សម្រាប់ឆ្នាំដំបូង សេវាទទួលស្គាល់ប្រចាំឆ្នាំត្រូវបង់នៅពេលដែលទទួលបានការទទួលស្គាល់។ សម្រាប់ឆ្នាំបន្តបន្ទាប់ សេវាទទួលស្គាល់ប្រចាំឆ្នាំត្រូវបង់យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃខែនៃការទទួលស្គាល់នៃឆ្នាំបន្តបន្ទាប់នោះ។

**ប្រការ ១៩**.-ការបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃសេវាទទួលស្គាល់

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃសេវាទទួលស្គាល់ប្រចាំឆ្នាំដែលបង់មក **គ.ម.ត.** មិនអាចដកវិញបានឡើយ ទោះជាបុគ្គលទទួលបាន ឬមិនទទួលបានការទទួលស្គាល់ ឬការទទួលស្គាល់ត្រូវបានព្យួរ ឬដកហូត។

## ជំពូកទី ៦

## ការផ្អាក និងការលុបចោលការទទួលស្គាល់

**ប្រការ ២០**.-ការផ្អាកការទទួលស្គាល់

អគ្គនាយកនៃ **គ.ម.ត.** អាចផ្អាកការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ឬសវនករឯករាជ្យ ក្នុងករណីដូចខាងក្រោម÷

១-ក្រុមហ៊ុនផ្តល់សេវាសវនកម្មមានសវនករឯករាជ្យដែលទទួលបានការទទួលស្គាល់ចំនួនតិចជាង ២ (ពីរ) រូប សម្រាប់រយៈពេល ៣ (បី) ខែជាប់គ្នា។

២-អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈចេញដោយ ក.ជ.គ. អស់សុពលភាព។

**ប្រការ ២១**.-ការលុបចោលការទទួលស្គាល់

អគ្គនាយកនៃ **គ.ម.ត.** អាចលុបចោលការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ឬសវនករឯករាជ្យ ក្នុងករណីវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬវិញ្ញាបនបត្របញ្ជាក់ជាសមាជិករបស់ស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ឬអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈចេញដោយ ក.ជ.គ. ត្រូវបានដកហូត។

**ប្រការ ២២**.-ការហាមឃាត់ការផ្តល់សេវាសវនកម្មក្នុងពេលផ្អាក ឬលុបចោលការទទួលស្គាល់

ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ឬសវនករឯករាជ្យ ដែលត្រូវបានផ្អាក ឬលុបចោលការទទួលស្គាល់ដូចមានចែងក្នុងប្រការ ២០ និងប្រការ ២១ នៃប្រកាសនេះ ត្រូវបញ្ឈប់ការផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រចាប់ពីកាលបរិច្ឆេទចេញលិខិតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ត.**។ ក្រុមហ៊ុនផ្តល់សេវាសវនកម្ម ឬសវនករឯករាជ្យដែលត្រូវបានផ្អាកការផ្តល់សេវាសវនកម្ម អាចចាប់ផ្តើមដំណើរការឡើងវិញបាន បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ត.**។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**ប្រការ ២៣.-វិធានការរដ្ឋបាល**

ករណីក្រុមហ៊ុនផ្តល់សេវាសវនកម្ម ឬសវនករឯករាជ្យ ប្រព្រឹត្តល្មើសនឹងកាតព្វកិច្ចដូចមានចែងក្នុងប្រការ ១០ ឬប្រការ ១១ នៃជំពូកទី ៣ ឬជំពូកទី ៤ ឬប្រការ ២២ នៃប្រកាសនេះ អគ្គនាយកនៃ **គ.ម.ក.** មានសិទ្ធិចាត់វិធានការពិន័យអន្តរការណ៍ និង/ឬ ទណ្ឌកម្មរដ្ឋបាលណាមួយដូចខាងក្រោម÷

១-ព្រមាន

២-ដឹកនាំកែតម្រង់

៣-ដាក់កំហិតលើការទទួលស្គាល់

៤-ព្យួរការទទួលស្គាល់

៥-ដកហូតការទទួលស្គាល់។

**ប្រការ ២៤.-វិធានការពិន័យអន្តរការណ៍**

ក្រុមហ៊ុនផ្តល់សេវាសវនកម្មដែលប្រព្រឹត្តល្មើសនឹងកាតព្វកិច្ចដូចមានចែងក្នុងប្រការ ១០ ឬប្រការ ១១ នៃជំពូកទី ៣ ឬជំពូកទី ៤ ឬប្រការ២២ នៃប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់មិនលើសពី ៥០.០០០.០០០ (ហាសិបលាន) រៀល។

សវនករឯករាជ្យដែលប្រព្រឹត្តល្មើសនឹងកាតព្វកិច្ចដូចមានចែងក្នុងប្រការ ១០ ឬប្រការ ១១ នៃជំពូកទី ៣ ឬជំពូកទី ៤ ឬប្រការ ២២ នៃប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់មិនលើសពី ២០.០០០.០០០ (ម្ភៃលាន) រៀល។

ក្នុងករណីក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យដែលបានទទួលស្គាល់ ដាក់ពាក្យស្នើសុំបន្តការទទួលស្គាល់នៅ **គ.ម.ក.** តិចជាង ៤៥ (សែសិបប្រាំ) ថ្ងៃ មុនកាលបរិច្ឆេទនៃការទទួលស្គាល់ចាស់អស់សុពលភាព ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ចំនួន ២០០.០០០ (ពីររយពាន់) រៀល ក្នុងមួយថ្ងៃ ចំពោះការដាក់ពាក្យស្នើសុំយឺតយ៉ាវនេះ។

ករណីក្រុមហ៊ុនផ្តល់សេវាសវនកម្ម ឬសវនករឯករាជ្យ បង់សេវាទទួលស្គាល់ប្រចាំឆ្នាំយឺតយ៉ាវ ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងសវនករឯករាជ្យ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុង ១ (មួយ) ថ្ងៃ សម្រាប់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងជាប្រាក់ចំនួន ១០.០០០ (ដប់ពាន់) រៀល ក្នុង ១ (មួយ) ថ្ងៃ សម្រាប់សវនករឯករាជ្យនីមួយៗ។

## ជំពូកទី ៨
## វិសោធនកម្មនូវបទបញ្ញត្តិជាធរមាន

**ប្រការ ២៥.-វិសោធនកម្មនូវបទបញ្ញត្តិមួយចំនួន**

បទប្បញ្ញត្តិដែលមានជាធរមាននៅក្នុងវិស័យមូលបត្រ ត្រូវធ្វើវិសោធនកម្មដូចខាងក្រោម÷

-ត្រូវកែឃ្លា “ក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ” ទៅជា “ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ”

-ត្រូវកែឃ្លា “ក្រុមហ៊ុនគណនេយ្យជំនាញ” ទៅជា “ក្រុមហ៊ុនផ្តល់សេវាសវនកម្ម”។

## ជំពូកទី ៩
## អវសានប្បញ្ញត្តិ

**ប្រការ ២៦.**-ការចេញគោលការណ៍ណែនាំ

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះ ដល់ក្រុមហ៊ុនផ្តល់សេវាសវនកម្ម សវនករឯករាជ្យ និងបុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងសាធារណជន។

**ប្រការ ២៧.**-បដិវាទកម្ម

ប្រកាសលេខ ០០៥/១០ គ.ម.ក./ប្រ.ក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីការទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រ ត្រូវទុកជានិរាករណ៍។

**ប្រការ ២៨.**-ការអនុវត្ត

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងយុត្តិធម៌
-ធនាគារជាតិនៃកម្ពុជា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
-ដូចប្រការ ២៨ “ដើម្បីអនុវត្ត”
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ